២៣៧-វរសេនីយ៍ឯក គាំ សុខុន ជំនួយការឯកឧត្តមទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី
២៣៨-វរសេនីយ៍ឯក ខុន ស្រេង ជំនួយការឯកឧត្តមទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី
២៣៩-វរសេនីយ៍ឯក ទ្រី ឆា ជំនួយការឯកឧត្តមអគ្គនាយកនគរបាលជាតិ
២៤០-វរសេនីយ៍ឯក នឹម ម៉ុនឡើង ជំនួយការឯកឧត្តមអគ្គនាយកនគរបាលជាតិ
២៤១-វរសេនីយ៍ឯក សុត ផុល ជំនួយការឯកឧត្តមអគ្គនាយកនគរបាលជាតិ
២៤២-វរសេនីយ៍ឯក ម៉ូរ ឡាមុនី ជំនួយការឯកឧត្តមអគ្គនាយកនគរបាលជាតិ
២៤៣-វរសេនីយ៍ឯក ថោង ទស្សនាវណ៌ ជំនួយការឯកឧត្តមអគ្គនាយកនគរបាលជាតិ

មាត្រា៤ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ

មាត្រា៥ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ ០៥ អនក្រ.បក

### ស្តីពី ការគ្រប់គ្រងព្រៃសម្បទាន

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៥ក្រ.ច ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

-បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ។

## សំរេច

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការគ្រប់គ្រង និងការអនុវត្តន៍ទៅលើរាល់សកម្មភាព ប្រមូលផលព្រៃឈើ កិច្ចព្រមព្រៀងព្រៃសម្បទានទាំងអស់ដែលបានផ្តល់អោយដោយរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណង ៖

-រៀបចំប្រព័ន្ធផែនការអនុវត្ត និង ត្រួតពិនិត្យព្រៃសម្បទាន ដើម្បីឈានទៅរកភាពប្រសើរក្នុងការអនុវត្តន៍បច្ចេកទេសនិងគ្រប់គ្រងផលិតផលព្រៃឈើប្រកបដោយនិរន្តរភាពនៅព្រះរាជាណាចក្រកម្ពុជា

-ធានានូវការគ្រប់គ្រង កាន់កាប់ព្រៃសម្បទាន ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ និងទិសដៅយូរអង្វែងក្នុងការរៀបចំធនធានចំរុះនិងរៀបចំដំណើរការផ្តល់ព្រៃសម្បទានអោយមានលក្ខណៈសមស្របនិងតម្លាភាពគ្រប់គ្រងព្រៃសម្បទាន ដើម្បីអភិរក្ស និងការពារជីវៈចំរុះធម្មជាតិ មុខងារប្រព័ន្ធ អេកូឡូស៊ីនិងសារៈសំខាន់ សេវាព្រៃឈើដូចជា ៖ ការអភិរក្សដី និងការគ្រប់គ្រងទីជំរាល

-ធានាអោយបានពេញលេញនូវទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការបំពេញមុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័នដែលមានភារកិច្ច និងការពង្វាកិច្ចក្នុងការរៀបចំ និងគ្រប់គ្រងព្រៃសម្បទានជាមួយភាគីពាក់ព័ន្ធទាំងអស់

-ធានានូវការចូលរួម និងពិគ្រោះយោបល់ពីសហគមន៍មូលដ្ឋាន ជាមួយម្ចាស់ព្រៃសម្បទាន និងស្ថាប័នគ្រប់គ្រងក្នុងការអភិវឌ្ឍន៍ផែនការគ្រប់គ្រងព្រៃសម្បទាន និងការតាមដានត្រួតពិនិត្យសកម្មភាពនៃដំណើរការប្រមូលផលព្រៃឈើលើសុពលភាពនៃព្រៃសម្បទាន

-ការពារ និងរក្សាសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ព្រៃសម្បទាន សំរាប់ជីវភាពសេដ្ឋកិច្ច ការចិញ្ចឹមជីវិត និងការគោរពជំនឿខាងសាសនា

-បង្កើតប្រព័ន្ធត្រួតពិនិត្យ និងការធ្វើផែនការគ្រប់គ្រងព្រៃឈើពីសក្រិត្យ ដែលនឹងផ្តល់ផ្លូវណែនាំ និងការលើកទឹកចិត្តដល់ឧស្សាហកម្មព្រៃឈើកម្ពុជាក្នុងការអនុវត្តន៍ប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើដែលអាចការទទួលស្គាល់ពីអន្តរជាតិ ។

មាត្រា ៣ .-

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋាន រុក្ខាប្រមាញ់) មានតួនាទីសំខាន់ក្នុងការតាមដានត្រួតពិនិត្យនិងគ្រប់គ្រងលើរាល់សកម្មភាពប្រមូលផលព្រៃឈើគ្រប់ប្រភេទ ដើម្បីធានានូវនិរន្តរភាពព្រៃឈើ។

អត្ថន័យនៃពាក្យបច្ចេកទេសដែលត្រូវបានប្រើប្រាស់នៅក្នុងអនុក្រិត្យនេះនឹងមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រិត្យនេះ ។

## ជំពូក ទី ២
## ការស្នើសុំ និង ការសំរេចផ្តល់ព្រៃសម្បទាន

មាត្រា ៤ .-

៤.១-ផ្អែកលើអនុសាសន៍ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) និងតាមការពិគ្រោះយោបល់ជាមួយនិងបណ្តាក្រសួងទាំងអស់ដែលពាក់ព័ន្ធ ព្រមទាំងសហគមន៍មូលដ្ឋាន គណៈរដ្ឋមន្ត្រីអាច សំរេចដាក់តំបន់ព្រៃផ្តល់ផលដែលនៅទំនេរ អោយទៅជាព្រៃសម្បទាន ដោយដាក់អោយដេញថ្លៃតាមលក្ខណៈប្រកួតប្រជែងជាសាធារណៈ ។ សំណើសុំព្រៃសម្បទានត្រូវលើកឡើងអោយស្របតាមគោលដៅនៃការអភិវឌ្ឍន៍ថ្នាក់ជាតិនិងខេត្ត ហើយស្របតាមផែនការប្រើប្រាស់ដីធ្លីរបស់មូលដ្ឋានដែលមានស្រាប់ ។

៤.២-អ្នកចូលរួមដេញថ្លៃ នឹងត្រូវបានទទួលយល់ព្រមអោយចូលរួមដេញថ្លៃ ចំពោះតែក្រុមហ៊ុនពាណិជ្ជកម្មណាដែលអាចជ្រើសរើសបញ្ចូលជាស្រេចនៅក្នុងបញ្ជីឈ្មោះ " ជ្រើសរើសជាមុន" ដែលបានរៀបចំ និងរក្សាទុកដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ។ ក្រុមហ៊ុនពាណិជ្ជកម្មដែលអាចជ្រើសរើសបញ្ចូលទៅក្នុងបញ្ជីឈ្មោះ "ជ្រើសរើសជាមុន" បាន លុះត្រាតែក្រុមហ៊ុននោះបានដាក់ពាក្យស្នើសុំ និងផ្តល់នូវតឹកតាងបញ្ជាក់ថា ៖

ក-មានសមត្ថភាពគ្រប់យ៉ាងក្នុងការគ្រប់គ្រងព្រៃឈើរួមមាន ៖ ការធ្វើផែនការ ការប្រមូលផលឈើ ការបន្តពូជឈើ ការថែរក្សាឈើឈរ ការការពារបរិស្ថាន និងទំនាក់ទំនងសហគមន៍

ខ-មានរបាយការណ៍បញ្ជាក់ថា អនុវត្តពីមុនបានល្អដោយគ្មានការរំលោភបច្ចេកទេសធ្ងន់ធ្ងរនៅក្នុងយុត្តាធិការនានា ដែលពួកគេធ្លាប់បានអនុវត្តនៅក្នុងដំណើរការប្រមូលផលកន្លងមក

គ-មានធនធានហិរញ្ញវត្ថុ និង បុគ្គលិកជំនាញគ្រប់គ្រាន់ដើម្បីអនុវត្តប្រតិបត្តិការព្រៃឈើយ៉ាងមានប្រសិទ្ធភាព ។

៥.៣-សំណុំឯកសារដេញថ្លៃទាំងអស់សំរាប់ដាក់អញ្ជើញអោយមានការចូលរួមដេញថ្លៃព្រៃសម្បទាន ត្រូវរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ដែលក្នុងនោះត្រូវមាន ៖

ក-កំណត់លក្ខណៈវិនិច្ឆ័យទាំងអស់ នៃការជ្រើសរើសដោយសេចក្ដីរៀបរាប់សំរាប់ការដេញថ្លៃព្រៃសម្បទាន

ខ-កំណត់បង្ហាញពីព្រំប្រទល់ព្រៃឈើជាក់ស្ដែង ដែលគ្រោងដាក់ដេញថ្លៃជាព្រៃសម្បទាន

គ-កំណត់បង្ហាញពីធនធាន ព្រៃឈើដែលអាចប្រមូលផលបាន និងតំបន់ហាមឃាត់អាជីវកម្ម ដោយសារហេតុផលខាងបរិស្ថាន សង្គមនិងវប្បធម៌ តាមរយៈការធ្វើសារពើភ័ណ្ឌបឋមសម្បទាន នៃតំបន់ព្រៃឈើ និងការអង្កេតស្វែងយល់ លើរូបភាពពីផ្កាយរណប ឬ រូបថតពីលើអាកាស និងការវាយតម្លៃជនបទបន្ទាន់

ឃ-អធិប្បាយពីតម្រូវការគ្រប់គ្រង និងលក្ខខណ្ឌការងារព្រៃសម្បទាន ដែលរាជរដ្ឋាភិបាលតំរូវអោយម្ចាស់ព្រៃសម្បទានអនុវត្ត ៖ ការធ្វើផែនការព្រៃឈើ ការការពារ និងគ្រប់គ្រងព្រៃឈើ ការអភិរក្ស និងការពារបរិស្ថាន ការពិគ្រោះយោបល់ និងសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការផ្ដល់មុខរបរដល់ប្រជាជនមូលដ្ឋាន ការអភិវឌ្ឍន៍ធនធានមនុស្ស ការផ្គត់ផ្គង់សំភារៈ និង សេវាកម្ម ការតាមដានពិនិត្យ និងវាយតំលៃការត្រួតពិនិត្យលើលិខិតអនុញ្ញាត និងបទដ្ឋានផ្សេងៗ និងការដាក់ពិន័យចំពោះការមិននុវត្តន៍តាម និងលក្ខខណ្ឌការងារផ្សេងទៀតក្នុងករណីចាំបាច់

ង-ភ្ជាប់មកជាមួយនូវច្បាប់ចំលងពីកិច្ចព្រមព្រៀងព្រៃសម្បទានជាគំរូ (ចំណុច ៥.១ ខាងក្រោម)

ច-កំណត់ច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យ សំរាប់វាយតំលៃការដេញថ្លៃព្រៃសម្បទាន ដែលត្រូវសំរេចដោយរាជរដ្ឋាភិបាលកម្ពុជា ។

៥.៤-ដំណើរការនៃការដាក់ព្រៃសម្បទានអោយដេញថ្លៃ តាមលក្ខណៈប្រកួតប្រជែងជាសាធារណៈ នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវរួមបញ្ចូលនូវបណ្ដាចំណុចចាំបាច់មួយចំនួនដូចខាងក្រោម ៖

ក-ដំណើរការប្រព្រឹត្តិទៅ នៃការដេញថ្លៃត្រូវស្ថិតនៅក្រោមការដឹកនាំរបស់គណៈកម្មការដេញថ្លៃមួយ ដែលមានសមាសភាពកំណត់ដោយប្រមុខរាជរដ្ឋាភិបាល

ខ-ត្រូវប្រកាសជាសាធារណៈនូវពេលវេលា និងទីកន្លែងដែលត្រូវធ្វើការដេញថ្លៃយ៉ាងតិចណាស់ ៩០ ថ្ងៃមុនពេលដេញថ្លៃ តាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានជាតិពីរកម្តងយ៉ាងតិច

គ-ត្រូវប្រកាសជាសាធារណៈពីប្រាក់កក់ ,ថវិកា និងមាតិកានៃឯកសារដែលត្រូវចូលរួមដេញថ្លៃ ដូចជា ៖ ការដេញថ្លៃជាទឹកប្រាក់ និងកិច្ចសន្យា ដើម្បីបំពេញអោយលក្ខខណ្ឌការងារ និងការរំពឹងទុកដែលមានចែងក្នុងមាត្រា ៤ ចំណុច៥-៧ ត និងព ខាងលើ

ឃ-គ្រប់អ្នកចូលរួមដេញថ្លៃត្រូវបង់ប្រាក់កក់ធានាបណ្ដោះអាសន្នក្នុងគណនីថវិកាជាតិ តាមរយៈក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋាន រុក្ខា-ប្រមាញ់) នៅពេលដាក់សំណុំលិខិតស្នើសុំចូលរួមដេញថ្លៃចំនួនប្រាក់កក់នេះ ត្រូវបានកំណត់ដោយគណៈកម្មការដេញថ្លៃព្រៃសម្បទាន ។

ង-ប្រកាសជាសាធារណៈដូចបានចែងក្នុងចំណុច (ខ) ខាងលើដោយត្រូវបញ្ជាក់ពីពេលវេលា និងទីកន្លែងដែលត្រូវធ្វើការដេញថ្លៃ និងអញ្ជើញជាផ្លូវការនូវអ្នកស្នើសុំដេញថ្លៃ និង បុគ្គលដែលមានការចាំបាច់ផ្សេងទៀត ដើម្បីចូលរួមក្នុងឱកាសបើកអោយដេញថ្លៃ

ច-មុននឹងបើកអោយដេញថ្លៃ ដោយផ្អែកលើអនុសាសន៍របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (នាយកដ្ឋាន រុក្ខា-ប្រមាញ់) គណៈរដ្ឋមន្ត្រីត្រូវកំណត់នូវតំលៃបំរុងសំរាប់ផ្ដល់អោយព្រៃសម្បទានជាមូលដ្ឋានសំរាប់ការដេញថ្លៃ ដោយអាចប្រកាស ឬមិនប្រកាសអោយដឹងជាមុនពេលដេញថ្លៃ

ឆ-នៅពេលវេលា និងទីកន្លែងដែលបានប្រកាសដូចមានបញ្ជាក់នៅក្នុងចំណុច

(ង) ខាងលើរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបើកបង្ហាញជាសាធារណៈនូវរាល់សំបុត្រស្នើសុំដេញថ្លៃជាទឹកប្រាក់ និងផ្នែកពាក់ព័ន្ធដទៃទៀតដូចមានចែងក្នុងសៀវភៅបន្ទុកដេញថ្លៃពីបណ្ដាអតិថិជន និងត្រូវប្រកាសពីចំនួនទឹកប្រាក់ដែលហ៊ានអោយថ្លៃក្នុងក្រោមសំបុត្រអតិថិជននីមួយៗជូនដល់គ្រប់អ្នកចូលរួម ដែលមានវត្តមាននាពេលដេញថ្លៃនោះ

ជ-បន្ទាប់ពីការដេញថ្លៃដូចមានចែងក្នុងចំណុច ឆ ខាងលើនេះរួចមក រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការប្រកាសឈ្មោះអ្នកមានឧត្តមភាព ដែលត្រូវជ្រើសរើសជាបេក្ខជនឈ្នះក្នុងការដេញថ្លៃព្រៃសម្បទាន ជាលក្ខណៈបណ្ដោះអាសន្ន រហូតដល់មានការសំរេចជាស្ថាពរពីរាជរដ្ឋាភិបាល

ឈ-ឯកសារដែលបានដាក់អោយចូលរួមដេញថ្លៃ ដូចមានចែងក្នុងចំណុច (គ) ត្រូវរក្សាទុកដោយអនុញ្ញាតអោយពិនិត្យជាសាធារណៈក្នុងរយៈពេល៦សប្ដាហ៍ បន្ទាប់ពីកំណត់បានអ្នកឈ្នះក្នុងការដេញថ្លៃ ។ ក្នុងអំឡុងពេលនេះ រាល់ភាគីពាក់ព័ន្ធក្នុងការដេញថ្លៃខាងលើទាំងអស់អាចធ្វើការប្ដឹងតវ៉ាពីការសំរេចក្នុងការដេញថ្លៃទៅរាជរដ្ឋាភិបាល

ញ-នៅពេលបញ្ចប់រយៈពេលកំណត់ប្រាំមួយសប្ដាហ៍ និងផ្អែកទៅលើការសំរេចដោយរាជរដ្ឋាភិបាល បេក្ខជនឈ្នះក្នុងការដេញថ្លៃ ត្រូវបានផ្ដល់ការយល់ព្រមជាស្ថាពរ

ដ-នៅពេលប្រកាសជាស្ថាពរនូវឈ្មោះអ្នកឈ្នះក្នុងការដេញថ្លៃ ប្រាក់កក់ធានាបណ្ដោះអាសន្ន ដែលបានបង់ដូចមានចែងក្នុងចំណុច (ឃ) នឹងត្រូវបានបង្វែរជូនវិញចំពោះអ្នកចាញ់ក្នុងការដេញថ្លៃ

ឋ-ប្រសិនបើអ្នកឈ្នះក្នុងការដេញថ្លៃពុំបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងព្រៃសម្បទាន ឬមិនបានបង់ប្រាក់បន្ថែមបង្គ្រប់តាមតម្លៃ ដែលដេញបានក្នុងអំឡុងពេល ៣០ថ្ងៃ ក្រោយពីមានការសំរេចជាស្ថាពរដូចមានចែងក្នុងចំណុច (ញ) ខាងលើ នោះប្រាក់កក់នឹងត្រូវបានរឹបអូសជាសម្បត្តិរដ្ឋដោយស្វ័យប្រវត្តិ ។

មាត្រា ៥ .-

៥.១- ព្រៃសម្បទានថ្មីត្រូវស្ថិតនៅក្រោមអភិបាលកិច្ចនៃគំរូកិច្ចព្រមព្រៀងព្រៃសម្បទានថ្មី ដែលនឹងត្រូវរៀបចំដោយក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ។ ចំពោះព្រៃសម្បទានដែលមានស្រាប់នឹងត្រូវស្ថិតនៅក្រោមអភិបាលកិច្ចនៃកិច្ចព្រមព្រៀងព្រៃសម្បទានថ្មី ដោយមានការយល់ព្រមទ្វេភាគី តាមរយៈការចរចារ ឬ នៅពេលផុតសុពលភាពនៃកិច្ចព្រមព្រៀងព្រៃសម្បទាន ដែលមាន ស្រាប់

៥.២- កិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវស្ថិតក្នុងទំរង់ការដែលកំណត់ដោយក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងយ៉ាងហោចណាស់ ត្រូវបញ្ជាក់ពី ៖

ក-កាលបរិច្ឆេទ និងរយៈពេលនៃការផ្តល់ព្រៃសម្បទាន

ខ-កំណត់អោយបានច្បាស់លាស់អំពីទំហំផ្ទៃដីព្រៃឈើ ដែលត្រូវផ្តល់ជាព្រៃសម្បទាន

គ-កំណត់អោយច្បាស់ណាស់នូវបរិមាណ និងប្រភេទនៃផលិតផលព្រៃឈើ ដែលអនុញ្ញាតអោយប្រមូលផល

ឃ-តំរូវការពីម្ចាស់ព្រៃសម្បទាននូវរាល់សំណុំឯកសារ ផែនការ របាយការណ៍ ការសិក្សាទិន្នន័យ និងពត៌មាន ដែលទាក់ទងទៅនឹងប្រសិទ្ធភាពនៃការការពារ និងគ្រប់គ្រងធនធានព្រៃឈើ

ង-កំណត់នូវលក្ខខ័ណ្ឌផ្សេងទៀត ដែលចាំបាច់ដើម្បីធានាដល់ដំណើរការគ្រប់គ្រងព្រៃសម្បទានដោយនិរន្តរភាព ។

៥.៣-នៅក្នុងអំឡុងពេលនៃសុពលភាពកិច្ចព្រមព្រៀងព្រៃសម្បទាន ត្រូវប្រគល់សិទ្ធិផ្តាច់មុខដល់ម្ចាស់ព្រៃសម្បទាន ដើម្បីអនុវត្ត ៖

ក-កិច្ចប្រតិបត្តិការគ្រប់គ្រង និងប្រមូលផលព្រៃឈើណាមួយនៅក្នុងតំបន់សម្បទានដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង

ខ-កិច្ចប្រតិបត្តិការដទៃទៀតនិងអនុវត្តការងារដែលបានយល់ព្រមតាមការចាំបាច់ សំរាប់គាំទ្រសកម្មភាពគ្រប់គ្រង និងប្រមូលផលដូចមានចែងនៅក្នុងចំណុច (ក) ។

៥.៤-ការបញ្ចប់កិច្ចព្រមព្រៀងព្រៃសម្បទានដោយការប្រគល់មកវិញ ការដកហូតដោយសារការអនុវត្តន៍ពុំបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ឬ ការអនុញ្ញាតអោយបន្តកិច្ចព្រមព្រៀងមុនពេលផុតសុពលភាព ត្រូវសំរេចដោយរាជរដ្ឋាភិបាល ។ ការលុបចោលកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយអោយស្របតាមនីតិវិធី ។ ព្រៃសម្បទាន

ដែលត្រូវបានដកហូត ឬ ប្រគល់មកវិញកន្លងមក ត្រូវរក្សាទុកជាតំបន់ព្រៃការពារធម្មជាតិ និងព្រៃរៀបចំដោយពួក និងមិនត្រូវបានផ្តល់អោយក្រុមហ៊ុនណាផ្សេងទៀតឡើយ ។

៥.៥-ក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ត្រូវសហការជាមួយអាជ្ញាធរដែនដី និង ម្ចាស់ព្រៃសម្បទានទាំងអស់ រៀបចំបង្កើតគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍អចិន្ត្រៃយ៍មួយ ដើម្បីធ្វើជាយន្តការសំរបសំរួលសំរាប់ពិភាក្សា និងផ្តល់យោបល់លើរាល់បញ្ហា ដែលពាក់ព័ន្ធរវាងម្ចាស់ព្រៃសម្បទាន និងបណ្តាសហគមន៍ជិតខាង ដែលមានទីតាំងនៅក្នុង ឬ ជិតតំបន់ព្រៃសម្បទានក្នុងគោលបំណងការពារ និងធានានូវសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់អាចជាប្រធានគណៈកម្មការអភិវឌ្ឍន៍ភូមិ ឬ ប្រធានអង្គការចាត់តាំងសង្គមមួយ ដែលមាននៅទីនោះ តាមរយៈការបោះឆ្នោត ។

៥.៦- ក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) អាចផ្តល់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតទៅភាគីផ្សេងទៀតក្រៅពីម្ចាស់ព្រៃសម្បទាន ដើម្បីធ្វើការប្រមូលអនុផលព្រៃឈើផ្សេងៗទៀតនៅក្នុងតំបន់ព្រៃសម្បទាន ។ ការផ្តល់នូវច្បាប់អនុញ្ញាតអោយប្រមូលអនុផលព្រៃឈើនេះ មិនត្រូវអោយមានបញ្ហា ឬទំនាស់ជាមួយនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់ម្ចាស់ព្រៃសម្បទាន ដែលបានរៀបចំឡើងដោយកិច្ចព្រមព្រៀងព្រៃសម្បទានឡើយ ។ លិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណប្រមូលអនុផលព្រៃឈើ មិនត្រូវផ្តល់អោយលើសពីរយៈពេល ១ឆ្នាំ ហើយអាចបន្តសុពលភាពបាន ដោយផ្អែកលើការស្នើសុំ ។ អាជ្ញាប័ណ្ណទាំងនេះត្រូវបានផ្តល់សំរាប់ការប្រមូលអនុផលព្រៃឈើដើម្បីលក់ ពុំមែនសំរាប់ការប្រមូលដើម្បីចិញ្ចឹមជីវិតជាប្រពៃណីក្នុងការប្រើប្រាស់ឯកជន ដោយប្រជាជនមូលដ្ឋាននោះឡើយ ។

៥.៧- ឯកសារវិនិយោគមុនព្រៃសម្បទានទាំងអស់ត្រូវបានផ្តល់ជូនចំពោះស្ថាប័នរបស់រាជរដ្ឋាភិបាល និង ភាគីដែលពាក់ព័ន្ធ តាមការស្នើសុំ ។

៥.៨- ចំពោះការគ្រប់គ្រងលើការធ្វើអាជីវកម្មធនធានធម្មជាតិដទៃទៀត ដែលស្ថិតនៅក្នុងដែនព្រៃសម្បទាន ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋតាមច្បាប់ជាធរមាន ។

## ជំពូកទី ៣
## ការធ្វើផែនការព្រៃសម្បទាន

មាត្រា ៦ .-

៦.១ - ការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាព នឹងទាមទារអោយមានការធ្វើផែនការចាំបាច់ទៅតាមកំរិត ទំហំ និង ពេលវេលា ហេតុនេះព្រៃសម្បទានត្រូវបែងចែកសំរាប់គោលបំណងនៃការធ្វើផែនការជាតំបន់គ្រប់គ្រង គូបប្រចាំឆ្នាំ និងប្លុកអាជីវកម្ម ។

៦.២ -ភាគនៃការធ្វើផែនការព្រៃសម្បទានត្រូវកំណត់សេចក្តីលម្អិតជាថ្នាក់ដូចខាងក្រោម ៖

ក-សេចក្តីអាតិកា និងការកិច្ចការងារនៃផែនការគ្រប់គ្រង ដោយពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកំណត់គោលបំណងនិង លក្ខណៈវិនិច្ឆ័យនៃការធ្វើផែនការគ្រប់គ្រងព្រៃឈើ សង្គម បរិស្ថាន និង ហិរញ្ញវត្ថុ

ខ-កំណត់ព្រំប្រទល់តំបន់ព្រៃឈើដោយផ្អែកលើការវាយតម្លៃផលប៉ះពាល់ដោយមានការចូលរួមសហគមន៍លើភព្វុនធនធានព្រៃឈើ បរិស្ថាន និងធ្វើផែនទី ដើម្បីកំណត់ ៖

-ផ្ទៃដីមិនធ្វើអាជីវកម្ម (តែងតែរួមជាមួយ តំបន់ប្រភពទឹក ផ្ទៃដីតាមដងស្ទឹង តំបន់ការពារ ព្រែក តំបន់ទេសចរណ៍ តំបន់ព្រៃសហគមន៍ និងតំបន់ត្រូវធ្វើការដាំដុះព្រៃឈើឡើងវិញ )

-ផ្ទៃដីធ្វើអាជីវកម្មសក្ដិសាព

គ-សេចក្តីផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែងសម្រាប់វដ្តព្រៃ ដែលអាចធ្វើអាជីវកម្មបាន ដោយការធ្វើសារពើភ័ណ្ឌ "កម្រិតគ្រប់គ្រង" ដោយបញ្ជាក់ពី ៖

-ប្រព័ន្ធវដ្តកម្មវប្បកម្មសមស្រប និងបច្ចេកទេសប្រមូលផលសមស្របនឹងព្រៃ និងស្ថានភាពភូមិសាស្ត្រខុសគ្នា ដោយផ្អែកលើការវាយតម្លៃនៃអតីត អំពីរបបប៉ះពាល់ធម្មជាតិ

-ទិន្នផលជានិរន្តរ៍រយៈពេលវែង និង អត្រាដែលកំណត់ពិតប្រាកដមានស្ថិតិទិន្នផលនិង អត្រាដំណុះរួមជាមួយនឹងអត្រាដកហូត ដែលធានានូវសមាសភាព រចនាសម្ព័ន្ធ និងមុខងារអេកូឡូស៊ីរបស់ព្រៃឈើ

-ការគ្រប់គ្រង "ការជះឥទ្ធិពល" ទៅលើសង្គមនិងបរិស្ថាន រួមនឹងកម្មវិធីតាមដានត្រួតពិនិត្យ

-កម្មវិធីចូលរួម ពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងជាមួយសហគមន៍មូលដ្ឋាន

-ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ឃ-សេចក្តីផែនការប្រតិបត្តិការប្រចាំឆ្នាំក្នុងវដ្តព្រៃគុប និងប្លុក អនុលោមតាមក្រមបច្ចេកទេសអនុវត្ត ដោយកំណត់បញ្ជាក់អំពី ៖

-វិធីសាស្ត្រ និងគ្រឿងចក្រ សម្រាប់ធ្វើអាជីវកម្ម

-មាឌឈើដែលត្រូវដកហូត

-ទំរង់ការនៃការដៅឈើ និងអូសទាញ

-ទីតាំងនិងតំរោងផ្លូវចូលទៅកាន់ព្រៃឈើ

-សកម្មភាពថែទាំឈើពីលើរ កូនឈើបន្តពូជ និងការដាំដុះដើមឈើឡើងវិញ

-ការការពារធនធានវប្បធម៌ និង បរិស្ថានលើកម្ពែងកំណត់ជាក់លាក់

-ការពិគ្រោះយោបល់ជាមួយសហគមន៍ប្រចាំឆ្នាំ

មាត្រា ៧ .-

៧.១- ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានគ្រប់កំរិតថ្នាក់ទាំងអស់ ត្រូវអនុវត្តការ និងប្រព្រឹត្តទៅតាមវិធានបច្ចេកទេស នៃការធ្វើផែនការ ដែលមានចែងនៅក្នុងក្រមបច្ចេកទេស អនុវត្តសំរាប់រៀបចំគ្រប់គ្រងព្រៃឈើ ។ គប់ផែនការគ្រប់គ្រងព្រៃឈើគ្រប់កំរិតថ្នាក់ទាំងអស់នឹងមិនត្រូវបានផ្តល់ការយល់ព្រមឡើយ ប្រសិនបើផែនការទាំងនោះមិនគោរពទៅតាមគំរិត និងមិនស្របទៅតាមគោលបំណង និងគោលការណ៍ណែនាំនៃក្រមបច្ចេកទេសអនុវត្តសំរាប់រៀបចំគ្រប់គ្រងព្រៃឈើ ។

៧.២- ក្រមបច្ចេកទេសអនុវត្តសំរាប់រៀបចំគ្រប់គ្រងព្រៃឈើ នឹងផ្តល់នូវវិធានសំរាប់ធ្វើផែនការគ្រប់គ្រងព្រៃសម្បទានដូចមានចែងនៅក្នុងមាត្រា ៦ខាងលើ រួមមាន ៖

ក-គោលការណ៍ណែនាំសំរាប់ធ្វើប្រព័ន្ធផែនការរៀបចំគ្រប់គ្រងព្រៃសម្បទាន

ខ-គោលការណ៍ណែនាំសំរាប់ធ្វើការពិភាក្សានៅក្នុងវគ្គរៀបចំ គ្រប់គ្រងព្រៃឈើ

គ-គោលការណ៍ណែនាំសំរាប់ការអភិវឌ្ឍចំរុះក្នុងដែនព្រៃឈើរៀបចំដោយឡែក

ឃ-គោលការណ៍ណែនាំសំរាប់សន្និធិព្រៃឈើក្នុងតំបន់ព្រៃសម្បទាន

ង-គោលការណ៍ណែនាំសំរាប់ការគ្រប់គ្រងទប់ស្កាត់ការលួចឈើ

ច-ក្រមបច្ចេកទេសអនុវត្តសំរាប់ប្រមូលផលព្រៃឈើ

ឆ-គោលការណ៍ណែនាំសំរាប់ការងារវិស្វកម្មព្រៃឈើ

ជ-គោលការណ៍ណែនាំសំរាប់រៀបចំតំបន់ពិសេស

ឈ-គោលការណ៍ណែនាំសំរាប់វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួងបរិស្ថាន ។

៧.៣- ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់ ) ត្រូវរៀបចំគោលការណ៍ណែនាំ និង ក្រមបច្ចេកទេស អនុវត្តសំរាប់រៀបចំគ្រប់គ្រង ព្រៃឈើចាំបាច់ផ្សេងទៀតដូចជា ៖ ការជ្រើសរើសប្រព័ន្ធវប្បកម្មព្រៃឈើ សន្តិកម្មព្រៃឈើ ការថែរក្សា និងបន្តពូជព្រៃឈើ ការរៀបចំគ្រប់គ្រងជំរកសត្វព្រៃ ការការពារផ្លូវទឹក និង ការតាមដានត្រួតពិនិត្យព្រៃឈើ ។

មាត្រា ៨ .-

ផ្អែកលើគោលការណ៍ឯកភាពរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផែនការទាំងនោះ នាយកដ្ឋាន រុក្ខា-ប្រមាញ់ ត្រូវផ្តល់នូវលិខិតអនុញ្ញាតប្រមូលផលព្រៃឈើ និងសៀវភៅបន្ទុកដែលជាលក្ខខណ្ឌបន្ថែមទៅអោយម្ចាស់ព្រៃសម្បទាន ដើម្បីចូលទៅធ្វើការប្រមូលផលព្រៃឈើនៅក្នុងព្រៃគូប ប្រចាំឆ្នាំ ។ ផែនការទាំងនេះ គឺជាទំរង់ការសំខាន់ចាំបាច់នៃលក្ខខណ្ឌអនុញ្ញាត និងជាមូលដ្ឋានសំរាប់វាយតំលៃការអនុវត្តន៍តាមបទបញ្ជាព្រៃឈើ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យតាមដាន និង ការអនុវត្តន៍បទបញ្ញត្តិ

មាត្រា ៩ .-

៩.១-ការត្រួតពិនិត្យតាមដានការប្រមូលផលព្រៃឈើ ត្រូវធ្វើឡើងជាពីរប្រភេទ ៖ ការត្រួតពិនិត្យតាមដានលក្ខខណ្ឌព្រៃឈើ និងការត្រួតពិនិត្យតាមដានការអនុវត្តន៍ច្បាប់ព្រៃឈើ ។

-ការត្រួតពិនិត្យតាមដាន លក្ខខណ្ឌព្រៃឈើ ធ្វើឡើងដើម្បីអង្កេតការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីព្រៃឈើចំពោះការប្រើប្រាស់ដី ការប្រមូលផលព្រៃឈើ ឬ ដំណើរការនៃការងាររុក្ខវប្បកម្ម

-ការត្រួតពិនិត្យតាមដាន ការអនុវត្តន៍ច្បាប់ព្រៃឈើ រៀបចំឡើងដើម្បីវាយតំលៃការអនុវត្តន៍ច្បាប់ ដូចមានចែងក្នុងផែនការ ដែលបានទទួលការយល់ព្រម និងលក្ខណលក្ខខណ្ឌ ដែលមានចែងនៅក្នុងសៀវភៅបន្ទុក និងលិខិតអនុញ្ញាតអោយប្រមូលផលព្រៃឈើ ។

៩.២-កម្មវិធីត្រួតពិនិត្យតាមដានលក្ខខណ្ឌព្រៃឈើ ត្រូវដាក់បញ្ញត្តិនៅក្នុងផែនការគ្រប់គ្រង ព្រៃឈើដែលនឹងត្រូវទទួល ខុសត្រូវដោយម្ចាស់ព្រៃសម្បទាន ។ ការត្រួតពិនិត្យតាមដាននេះរួមមាន ៖

ក-ត្រួតពិនិត្យមើលលក្ខខណ្ឌនៃការប្រើប្រាស់ដីធ្លី

ខ-ត្រួតពិនិត្យមើលដំណុះកូនឈើ មុន និងក្រោយពេលប្រមូលផលព្រៃឈើ និងលក្ខខណ្ឌឈើឈរ

គ-ត្រួតពិនិត្យតាមដានមើលប្រភេទសត្វព្រៃដែលមានស្រាប់

ឃ-ត្រួតពិនិត្យតាមដានមើលរុក្ខជាតិក្នុងព្រៃមុន និងក្រោយពេលប្រមូលផលព្រៃឈើ

ង-ធ្វើការអង្កេតឡើងវិញអោយបានទូលំទូលាយនូវ លក្ខណៈជីវៈចំរុះក្នុងតំបន់ព្រៃសម្បទានសំរាប់ចន្លោះពី៥-១០ឆ្នាំ ។

ប្រភេទនៃការត្រួតពិនិត្យតាមដាននេះត្រូវអោយមានស្តង់ដាត្រួតពិនិត្យខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រ និង ស្ថិតិ ហើយអាចយកទៅអនុវត្តបានជាមួយនឹងជំនួយការបច្ចេកទេស នៃអង្គការអន្តរជាតិ តាមការចាំបាច់ ។

៩.៣-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ត្រូវរៀបចំក្រុមត្រួតពិនិត្យតាមដានមើលការអនុវត្តមន៏រាល់បទបញ្ញត្តិប្រមូលផលព្រៃឈើសំរាប់ព្រៃសម្បទាននិមួយៗ ដោយកំណត់តួនាទីនិងភារកិច្ចអោយបានច្បាស់លាស់ ។ ក្រុមនេះនឹងត្រូវធ្វើអធិការកិច្ចព្រំប្រទល់ព្រៃសម្បទាន និង ត្រួតពិនិត្យមើលដំណើរការនៃការប្រមូលផលព្រៃឈើក្នុងព្រៃគុបប្រចាំឆ្នាំ និងប្លុក ហើយត្រូវពិនិត្យមើលនូវរាល់សកម្មភាពបទល្មើសដែលកើតមាននៅក្នុងតំបន់ព្រៃសម្បទាន ដើម្បីចាត់វិធានការតាមច្បាប់ ។ រាល់ការធ្វើអធិការកិច្ចត្រូវប្រើប្រាស់នូវឯកសារបទដ្ឋាននៃទំរង់របាយការណ៏ ត្រួតពិនិត្យ ដូចមានចែងក្នុងជំពូក ១៤ នៃក្រមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើ ។ ក្រុមការងារនេះនឹងត្រូវធ្វើការវាយតំលៃពីការបំពេញការងារនៅក្នុងប្លុក និងលើកជាអនុសាសន៏ទៅនាយកដ្ឋាន រុក្ខា-ប្រមាញ់ ស្តីពីការបិទប្លុកមុននឹងយល់ព្រមអោយបើក ប្លុក ថ្មីទៀត ។ នាយកដ្ឋាន រុក្ខា-ប្រមាញ់ ត្រូវរៀបចំរបាយការណ៏ត្រួតពិនិត្យតាមដានការអនុវត្តន៏

បទប្បញ្ញត្តិប្រចាំឆ្នាំសំរាប់ព្រៃសម្បទាននិមួយៗ ម្ចាស់សម្បទានបញ្ជូនរបាយការណ៍ទាំងនេះទៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យ និងស្វែងរកមតិកែលំអពីអ្នកពាក់ព័ន្ធ ពីសាធារណៈមតិ ។

៩.៤-ម្ចាស់ព្រៃសម្បទានទាំងអស់ អាចបង្កើតជាកម្មវិធីត្រួតពិនិត្យ តាមដានរបស់ខ្លួនផ្ទាល់សំរាប់ត្រួតពិនិត្យ ការងារផ្ទៃក្នុង ឬសំរាប់ធានាការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធភាពខ្ពស់ ។

៩.៥-នៅរៀងរាល់៥ឆ្នាំ ម្តងនៃការអនុវត្តន៍ ផែនការគ្រប់គ្រងព្រៃសម្បទាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (នាយកដ្ឋានរុក្ខា-ប្រមាញ់) ត្រូវពិគ្រោះយោបល់ជាមួយម្ចាស់ព្រៃសម្បទាន និងគណៈកម្មាធិការ ពិគ្រោះយោបល់សហគមន៍ ដើម្បី ៖

១-ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ដែលបានអនុវត្តន៍

២-វាយតំលៃលើប្រសិទ្ធភាពនៃលិខិតបទដ្ឋាន ក្រមបច្ចេកទេសអនុវត្តសំរាប់រៀបចំគ្រប់គ្រងព្រៃឈើ និង គោលការណ៍ណែនាំ ព្រមទាំងបទប្បញ្ញត្តិគ្រប់គ្រងព្រៃឈើដទៃទៀត

៣-កំណត់ពីការកែលំអបន្ថែមលើផែនការគ្រប់គ្រងព្រៃសម្បទាន ដែលចាំបាច់ដើម្បីជំរុញការអនុវត្តន៍ អោយបានល្អប្រសើរ ។

## ជំពូក ទី៥

## ទោសប្បញ្ញត្តិ

**មាត្រា១០ .-**

១០-១ ក្នុងករណីមិនបានអនុវត្តតាមការតព្វកិច្ចទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងព្រៃសម្បទាន ឬផែនការរៀបចំគ្រប់គ្រងព្រៃឈើ នាយកដ្ឋានរុក្ខា-ប្រមាញ់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការខកខានមិនបានបំពេញកាតព្វកិច្ចនេះទៅសាមីក្រុមហ៊ុនព្រៃសម្បទាន ។ ប្រសិនបើមានការខូចខាតកើតឡើងដោយសារកាមិនបានបំពេញកាតព្វកិច្ចនេះ សាមីក្រុមហ៊ុនព្រៃសម្បទាននឹងត្រូវបានផ្តល់រយៈពេលកៅសិបថ្ងៃ (៩០) ដើម្បីជួសជុលការខូចខាតទាំងនោះ ប្រសិនបើសាមីក្រុមហ៊ុនព្រៃសម្បទាននោះខកខាន មិនបានជួសជុលការខូចខាតនោះទេ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការវាយតំលៃអំពីការខូចខាតដែលកើតមាន ។

១០-២ ដោយមិនគិតពីអានុភាពនៃច្បាប់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ក្នុងករណីមានការបំពានលើបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងព្រៃសម្បទាន ឬផែនការរៀបចំគ្រប់គ្រងព្រៃឈើ រាជរដ្ឋាភិបាលអាចតំរូវអោយសាមីក្រុមហ៊ុនព្រៃសម្បទានបង់សំណងនៃការខូចខាតទៅតាមលទ្ធផលនៃការវាយតំលៃរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១០-៣ ក្នុងករណីមានការរំលោភ បំពានម្តងហើយម្តងទៀតទៅលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងព្រៃសម្បទាន និងផែនការរៀបចំគ្រប់គ្រងព្រៃឈើ ហើយបើមានការរំលោភបំពាននេះស្ថិតនៅគ្មានការជួសជុលក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ រាជរដ្ឋាភិបាលមានភារកិច្ចប្រកាសព្យួរ ឬ បញ្ឈប់ការធ្វើអាជីវកម្មព្រៃសម្បទាននេះ ។

១០-៥ សកម្មិក្រុមហ៊ុនព្រៃសម្បទាននឹងត្រូវបាត់បង់អោយការបោះបង់ចោលវត្ថុការពារ សិទ្ធិ ឬ ដោះដើ ឈើឬ ធនធានធម្មជាតិដទៃទៀត ដែលទទួលបានក្នុងរយៈពេលនៃការបំពានលើកិច្ចព្រមព្រៀងព្រៃសម្បទាន និងផែនការរៀបចំគ្រប់គ្រងព្រៃឈើ ។

## ជំពូក ទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួន ។

**មាត្រា១៣ .-**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

**ឈា សុខ**

***

## ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០០

## និយមន័យ នៃពាក្យបច្ចេកទេស

- **បរិមាណឈើអនុញ្ញាតអោយកាប់ប្រចាំឆ្នាំ** មានន័យថាបរិមាណដែលអាចប្រមូលផលបានក្នុងឆ្នាំនិមួយៗ ពីតំបន់ព្រៃសម្បទានណាមួយ ដោយរក្សាបាននូវប្រព័ន្ធ អេកូឡូស៊ី និង មិនត្រូវធ្វើការប្រមូលផលអោយហួសពីលទ្ធភាពព្រៃឈើផ្តល់អោយ ។ បរិមាណឈើដែលអនុញ្ញាតអោយកាប់ប្រចាំឆ្នាំអាច ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែត្រូវអោយមានគុណភាពនូវកំរិតនិរន្តរភាពលើសពីរយៈពេល១០ឆ្នាំ ។

- **ផែនការប្រមូលផលប្រចាំឆ្នាំ** មានន័យថាការរៀបចំ ដែលកំណត់នូវការអនុញ្ញាតិនៅក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រងប្រាំឆ្នាំសំរាប់ការអភិវឌ្ឍន៍ ការប្រមូលផលព្រៃឈើ ការបណ្តុះឡើងវិញ សកម្មភាពអនុវត្តក្នុងរយៈពេលមួយឆ្នាំនៅក្នុងតំបន់ប្រមូលផលដែលធ្វើតាមគោលការណ៍នៃផែនការគ្រប់គ្រងព្រៃឈើ ។
- **ជីវចំរុះ** មានន័យថា ការភាពចំរុះនៃរុក្ខជាតិ សត្វ និងភាវៈរស់ផ្សេងៗនៅតាមដែនដី និងតាមអាកាសធាតុ គ្រប់លំដាប់ថ្នាក់ របស់វាដូចជា ៖ ហ្សែន កោសិកា ពូជ ប្រភេទ ប្រព័ន្ធអេកូឡូស៊ី និងដំណើរការវិវត្តន៍ និងមុខងារ ដែលទាក់ទងជាមួយជីវចំរុះ ។
- **ប្លុក** មានន័យថា ការចែកតំបន់គ្រប់គ្រងតូចបំផុត ហើយមានមុខងារជាឯកតាមួយសំរាប់ត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្មប្រមូលផលព្រៃឈើ ។
- **សៀវភៅបន្ទុក** មានន័យថា ជាលិខិតកំណត់គោលការណ៍ និងលក្ខខ័ណ្ឌបច្ចេកទេសដែលត្រូវអនុវត្តក្នុងការធ្វើអាជីវកម្មព្រៃឈើ និងលក្ខខ័ណ្ឌទទួលខុសត្រូវរបស់អ្នកទទួលព្រៃគុប សំដៅធានាគុណភាពរវាងការធ្វើអាជីវកម្ម ការបណ្តុះឈើ ការការពារព្រៃ និងការតម្រៀវតៃឈើ ។
- **ក្រមបច្ចេកទេសអនុវត្តន៍គ្រប់គ្រងព្រៃឈើ** មានន័យថា ជាសំណុំបញ្ញត្តិបច្ចេកទេសសំរាប់ការគ្រប់គ្រងព្រៃឈើ ក្នុងគោលបំណងណែនាំធ្វើផែនការគ្រប់គ្រង និងការអនុវត្តន៍នៅគ្រប់លំដាប់ថ្នាក់ ។
- **ព្រៃគុប** មានន័យថា ជាមូលដ្ឋាននៃតំបន់ព្រៃឈើនីមួយៗ ដែលបានបង្កើតឡើងដោយមានការកំណត់ទីតាំងភូមិសាស្ត្រច្បាស់លាស់ ដែលការប្រមូលផលព្រៃឈើប្រចាំឆ្នាំ និងប្រើប្រាស់ជាមូលដ្ឋានសំរាប់ធ្វើការកត់ត្រាជាប្រចាំលើកិច្ចដំណើរការព្រៃឈើទាំងអស់ ។
- **ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន** មានន័យថា គ្រប់សកម្មភាព ដែលធ្វើឡើងដើម្បីកំណត់ហេតុប៉ះពាល់ទៅលើធនធានធម្មជាតិ ធនធានអេកូឡូស៊ី សុខភាពសាធារណៈ និងសុខុមាលភាពសង្គម ។
- **ព្រៃឈើ** មានន័យថា ជាប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិចំរុះ ដី ទឹក រុក្ខជាតិ មីក្រូសរីរាង្គ .... ដែលនៅលើផ្ទៃដី ត្រូវបានគ្របដណ្តប់ដោយគំរបរុក្ខជាតិឈើ ឬ ឫស្សីលើសពី១០ % និងមានផ្ទៃដីលើសពី០.៥ ហ.ត ឡើងទៅ ដែលរួមមាន ៈ សារព័ន្ធព្រៃគំរបជិត ដែលមានរុក្ខជាតិឈើច្រើនស្រទាប់ខុសគ្នានឹងរុក្ខជាតិស្រទាប់ក្រោម គ្របដណ្តប់ភាគច្រើនលើផ្ទៃដី ឬ សារព័ន្ធព្រៃចំហរ ដែលមានគំរបរុក្ខជាតិជាប់ៗគ្នា ក្នុងនោះរុក្ខជាតិឈើគ្របដណ្តប់លើសពី ១០% ។ រីឯព្រៃធម្មជាតិក្មេង និង ព្រៃដាំសំរាប់គោលបំណងព្រៃឈើ ដែលមានដង់ស៊ីតេគំរបស្លឹកមិនទាន់ដល់ ១០% នៅឡើយ ឬផ្ទៃដីអតីតព្រៃឈើ ដែលរេចរិលដោយសារឥទ្ធិពលរបស់មនុស្ស ឬមូលហេតុធម្មជាតិ ប៉ុន្តែសង្ឃឹមថាអាចជួសជុលកែលំអឡើងវិញបានក៏ត្រូវចាត់ថ្នាក់ជាព្រៃឈើដែរ ។
- **ព្រៃសម្បទាន** មានន័យថា ជាតំបន់ព្រៃឈើណាមួយ ដែលរាជរដ្ឋាភិបាលបានផ្តល់ទៅអោយក្រុមហ៊ុនឯកជន តាមរយៈការចរចា ឬ ដេញថ្លៃនូវសិទ្ធិ និង ការទទួលខុសត្រូវលើការគ្រប់គ្រង និងប្រមូលផលលើផ្ទៃដីកំណត់សមស្របទៅតាមលក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ។

- **កិច្ចព្រមព្រៀងព្រៃសម្បទាន** មានន័យថា ជាកិច្ចព្រមព្រៀង ឬកិច្ចសន្យារវាងរាជរដ្ឋាភិបាលកម្ពុជា និងបុគ្គល ១នាក់ ឬ ក្រុមហ៊ុនពាណិជ្ជកម្ម ដែលទទួលសិទ្ធិកាន់កាប់តំបន់ព្រៃឈើដើម្បីធ្វើអាជីវកម្មប្រមូលផលព្រៃឈើទៅតាមល័ក្ខខ័ណ្ឌនៃបទប្បញ្ញត្តិ ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ។
- **ផែនការគ្រប់គ្រងព្រៃឈើ** មានន័យថា ជាឯកសារមួយដែលធ្វើឡើងដោយផ្អែកលើគោលនយោបាយព្រៃឈើជាតិនិងធនធានធម្មជាតិ ដាក់បញ្ចូលទៅក្នុងការរៀបចំកម្មវិធីសំរាប់រយៈពេលវែងគ្រប់គ្រងព្រៃសម្បទានទាំងមូល ដូចជា ÷ ការកំណត់តំបន់ព្រៃឈើ និង បទបញ្ញាប្រមូលផលព្រៃឈើ និងសកម្មភាពខាងបរិស្ថានសង្គម ក្នុងរយៈពេលកំណត់មួយ (១៥ ឆ្នាំ) តាមរយៈការប្រើប្រាស់បទប្បញ្ញត្តិ ដែលមានគោលដៅមួយទំនួលការប្រកបដោយសកម្មភាពគ្រប់គ្រងតាមដាន និង ត្រួតពិនិត្យច្បាស់លាស់ ។
- **ផលិតផលព្រៃឈើ** រួមមាន ÷

  ក-ឈើមូល ឈើកែច្នៃ ធ្យូង អុស សំបកឈើ និង ផលិតផលដែលទាញចេញពីសំបកឈើ

  ខ-ជ័រឈើគ្រប់ប្រភេទ ឫស ស្លឹក ផ្កា ផ្លែ គ្រាប់ធ្មេញ វល្លិ៍ ឫស្សី ឬស្សីគ្រប់ប្រភេទ រុក្ខជាតិផលិតជាផលិតផលឱសថ គ្រឿងសំអិតសំអាង គ្រឿងទេស ចំណីសត្វ ផលិតផលវប្បធម៌សំរាប់ពិធីបុណ្យ សំភារៈសំណង់ និងស្បូវ ដែលទាញយកពីព្រៃឈើ ព្រៃគម្ពោធ និងរុក្ខជាតិផ្សេងៗទៀតងាប់ ឬ នៅរស់ ។

  គ-ផលិតផលព្រៃឈើផ្សេងៗទៀត និងផលប្រមាញ់គ្រប់ប្រភេទ ដែលគ្មានចែងនៅក្នុងអនុក្រឹត្យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើការប្រកាសជាផលិតផលព្រៃឈើបាន ។
- **គោលការណ៍ណែនាំ** មានន័យថា ជាសំណុំបទប្បញ្ញត្តិធ្វើផែនការ និងប្រតិបត្តិការប្រមូលផលព្រៃឈើដែលមិនមានការចាំបាច់គ្រប់ពេលវេលា ប៉ុន្តែវាអាចក្លាយទៅជាលក្ខខ័ណ្ឌនៃការអនុវត្តន៍ ដែលមានចែងនៅក្នុងផែនការលិខិតអនុញ្ញាត និង កិច្ចសន្យា (ដូចគ្នាទៅនឹងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើ) ។
- **ព្រៃឈើអចិន្រ្តៃយ៍** មានន័យថា ជាតំបន់ដី ដែលមានកំណត់ទីតាំងភូមិសាស្ត្រច្បាស់លាស់ និងស្របច្បាប់នៃគ្រប់ប្រភេទកម្មសិទ្ធ ដែលរួមមានព្រៃ និងព្រៃផ្តល់ផលដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋ ម្ចាស់ព្រៃសម្បទាន សហគមន៍មូលដ្ឋាន និងអ្នកប្រើប្រាស់ព្រៃឈើផ្សេងៗទៀតសំរាប់រយៈពេលវែងក្នុងការទាញយកផលពីព្រៃឈើ ដោយនិរន្តរភាព និងថែទាំនូវសមាសភាព និងរចនាសម្ព័ន្ធព្រៃ ព្រមទាំងតួនាទីបរិស្ថាន ។
- **ធនធានធម្មជាតិ** មានន័យថា ជាផលដែលកើតមានឡើងដោយធម្មជាតិនៅក្នុងដី ឬនៅលើផ្ទៃដីនៃតំបន់ព្រៃសម្បទាន ដូចជាកំណប់រ៉ែ លោហធាតុ ឧស្ម័ន ប្រេងកាត ត្បូង ថ្ម ដីខ្សាច់ ទឹក ... ។ល។ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋតាមច្បាប់ជាធរមានផ្សេងៗទៀត ។
- **ថ្លៃមុំរុខ** មានន័យថា តម្លៃអប្បបរមាដែលរាជរដ្ឋាភិបាលកម្ពុជានឹងយល់ព្រមនៅក្នុងដំណើរការដេញថ្លៃសំរាប់ផ្តល់ព្រៃសម្បទានណាមួយ ។ តម្លៃមុំរុខអាចត្រូវបាន ឬក៏មិនត្រូវបានប្រកាសជាចំហរមុនពេលចាប់ផ្តើមដំណើរការដេញថ្លៃ ។

- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មានន័យថា ជាអង្គការជ្រើសតាំងនៅថ្នាក់ភូមិ ដែលបង្កើតឡើងដោយ អនុក្រឹត្យស្ថិតនៅក្រោមគម្រោងអភិវឌ្ឍន៍ជនបទ ដើម្បីផ្តល់ជាយោបល់ទៅរាជរដ្ឋាភិបាល ស្តីពីតម្រូវការអភិវឌ្ឍន៍មូលដ្ឋាន និងការផ្តួចផ្តើមគំនិត ។
- តំបន់ មានន័យថា ជាអនុផ្នែកនៃប្រែសស្សរោន ដែលមានលក្ខណៈជាអេកូឡូស៊ី ជីវៈរូបសាស្ត្រ ឬ ពំរែ ធនធាន ដែលត្រូវអោយមានការគ្រប់គ្រងដោយឡែកពីតំបន់ដែលនៅជាប់ៗគ្នា ។

***

## អនុក្រឹត្យ ៥២ អនក្រ.បក

## ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត//១០៩៥/០១ ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ ប្រកាសប្រើគ្រឿង ឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

### សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយធិបឌិន្ទមុនីសារាភ័ណ្ឌ ប្រគេនព្រះទេពសត្ថា ឈាយ ច្រឹក ព្រះរាជាគណៈថ្នាក់ ឯក ព្រះអនុគណស្រុកពញាឮ និងជាព្រះចៅអធិការវត្ត ចន្ទបូរីវង្ស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ដែលបានលះបង់ព្រះកាយពល និងបច្ច័យផ្ទាល់ព្រះអង្គជាច្រើន សំរាប់ចូលរួមស្តារ និងកសាងវិស័យសិក្សាធិការជាតិ ព្រះពុទ្ធសាសនា និងការងារសង្គមកិច្ច ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ហ្លួលោធា និងព្រា**

**ហ៊ុន សែន**